## ប្រភពនៃភស្តុតាង (ប្រទេសបារាំង) Richard Vogler ( Richard Vogler and Barbara Huber, Criminal Procedure in Europe, 2008, pp. 243-252)

**ពាក្យគន្លឹះ÷** ប្រភេទនៃភស្តុតាង ការទទួលយក វិធាននៃភស្តុតាង

១. ក្នុងសំណុំរឿងព្រហ្មទណ្ឌ មានភស្តុតាងជាច្រើនប្រភេទ ត្រូវបានប្រមូលក្នុងអំឡុងពេលស៊ើបអង្កេតបឋម និងស៊ើបសួរដោយតុលាការ។ ភស្តុតាងទាំងនោះមានដូចជា÷ សក្ខីកម្មសាក្សី របាយការណ៍អ្នកជំនាញ (report of expert) ឯកសារ ភស្តុតាងរូបវន្ត (material evidence) ឬចម្លើយសារភាព។

២. ប្រព័ន្ធច្បាប់ប្រទេសបារាំង ប្រកាន់យកវិធាននៃភស្តុតាងដោយសេរី ក្នុងន័យថា សូម្បីចម្លើយសារភាព ក៏អាចទទួលយកទៅពិនិត្យនិងពិចារណាផងដែរ។

៣. សាក្សី មានច្រើនប្រភេទ អាចជាអ្នកឃើញហេតុការណ៍កើតមានឡើង។ សាក្សី ខុសពីអ្នកគ្រាន់តែផ្តល់ព័ត៌មាន (mere informant)។ មន្ត្រីតុលាការ ដូចជា ក្រឡាបញ្ជី ចៅក្រម (លើកលែងនរគបាល) មិនអាចជាសាក្សី ផ្តល់ភស្តុតាង ក្នុងរឿងដែលពួកគេបានជាប់ពាក់ព័ន្ធ។ សាក្សីត្រូវបានតម្រូវឱ្យចូលខ្លួនតាមការកោះហៅ និងឆ្លើយដោយស្បថ ករណីខកខាន អាចនាំឱ្យមានការបង់ពិន័យ។ សាក្សីខ្លះ ជាអ្នកប្រកបវិជ្ជាជីវៈ ដូចជា វេជ្ជបណ្ឌិត មេធាវី ត្រូវគោរពគោលការណ៍សម្ងាត់។ សាក្សី អាចផ្តល់ភស្តុតាងស្តីពីអង្គហេតុ ឬចរិតរបស់ជនសង្ស័យ (witness of character) ឬ បញ្ជាក់លើវត្ថុ ឬភស្តុតាងរូបវន្ត ដែលរឹបអូសបាន។

៤. របាយការណ៍អ្នកជំនាញ ផ្តួចផ្តើមដោយនរគបាល ឬដោយភាគី។ ពួកគេត្រូវជ្រើសរើស ចេញពីបញ្ជី។ ចៅក្រមស៊ើបសួរ អាចបដិសេធសំណើសុំអ្នកជំនាញ ហើយភាគីអាចប្តឹងទៅសភាស៊ើបសួរ ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធ។ សម្រាប់ប្រភពនៃភស្តុតាង ជាឯកសារវិញ វាកាន់តែសំខាន់ដោយសារ គោលការណ៍ផ្ទាល់មាត់ (principle of orality) ដែលប្រទេសបារាំងប្រកាន់យកនាសម័យមុន ត្រូវបានកម្រិតច្រើន។ ទីនេះ គេគួរតែមានការបែងចែកអំពីប្រភេទនៃឯកសារ។ process verbal (PV) ជាប្រភេទមួយអាចត្រូវបានធ្វើដោយនគរបាល មានតម្លៃត្រឹមតែជាព័ត៌មាន ដែលផ្ទុយគ្នានឹងឯកសារដោយចៅក្រមស៊ើបសួរ គឺជាភស្តុតាង លើកលែងតែ ត្រូវបានមោឃភាព ដោយសារវិការៈ។ ដើម្បីជៀសវៀងនូវមោឃភាព PV ត្រូវផ្ទុកនូវព័ត៌មាន ចាំបាច់មួយចំនួនដូចជា ឈ្មោះអ្នកចូលរួម ...។ គេអាចធ្វើខ្លឹមសារសង្ខេប ក៏ប៉ុន្តែតម្រូវឱ្យមានការថត (recorded) នូវសំណួរ និងចម្លើយឱ្យបានត្រឹមត្រូវ។

៥. ភស្តុតាងរូបវន្ត ជាអ្វីប្រមូលពីកន្លែងកើតហេតុ (exhibits) ហើយដែលមន្ត្រីនរគបាលយុត្តិធម៌ត្រូវរំពឹងថានឹងចុះទៅពិនិត្យនិងប្រមូល។ ភស្តុតាងនេះ អាចទទួលបានពីការចុះទៅស្រាវជ្រាវទីតាំងផ្សេង (search and seizure)។ ការចូលទៅក្នុងទីតាំងនោះ ត្រូវអនុលោមតាមពេលវេលា និងនីតិវិធីតម្រូវដោយច្បាប់ លើកលែងបទល្មើសជាក់ស្តែង។ មានសំភារៈមួយប្រភេទទៀត គឺការ telecommunication interceptions ដូចជាការចូលទៅមើលអ៊ីមេលជនសង្ស័យ។ សាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប នាំឲ្យមានការហាមឃាត់របៀបយកភស្តុតាងដូចនេះ។ ការអនុញ្ញាតធ្វើ ត្រូវបានកំណត់សម្រាប់រយៈពេលកំណត់៤ខែ អាចពន្យាជាផ្លូវការ និងស្ថិតនៅក្រោមការពិនិត្យរបស់ចៅក្រម។

៦. សម្រាប់ចម្លើយសារភាពវិញ តុលាការបារាំងទទួលយកផ្នែកខ្លះ មិនយកផ្នែកខ្លះ។ ចម្លើយសារភាព អាចកើតមានក្នុងអំឡុងស៊ើបអង្កេតបឋម នឹងអាចត្រូវដកចេញដោយចៅក្រមស៊ើបសួរ តាមរយៈការស្នើសុំរបស់ជនជាប់ចោទ។ វិធីសាស្ត្រមួយចំនួន ដើម្បីបានចម្លើយសារភាព ត្រូវបានហាមឃាត់ ដូចជាការសាកសួរក្នុងរយៈពេលយូរ ការប្រើវិធីរិះរកការភូតកុហក (lie detector) ឬការប្រើទារុណកម្ម។ ចម្លើយសារភាពតាមវិធីនេះ នឹងត្រូវបានបដិសេធ តាមរយៈនីតិវិធីមោឃភាព។

......................................

ពាក់ព័ន្ធនឹងភស្តុតាង វាពាក់ព័ន្ធនឹងបន្ទុកភស្តុតាងនិងកម្រិតភស្តុតាងផងដែរ។ មានបន្ទុក និងកម្រិតភស្តុតាងជាច្រើនប្រភេទ។ អ្វីគួរកត់សំគាល់ គឺថា ជនជាប់ចោទជាអ្នកអះអាងថា ចម្លើយសារភាពត្រូវបានធ្វើឡើងតាមរយៈទារុណកម្ម ហើយរដ្ឋអាជ្ញាមានបន្ទុកភស្តុតាងបង្ហាញថា ចម្លើយសារភាពមិនត្រូវបានទទួលដោយប្រើទារុណកម្មទេ។ ការទាមទារនេះ ដោយសាររដ្ឋអាជ្ញា មានលទ្ធភាពអាចបង្ហាញបានខណៈជនជាប់ចោទមិនអាចរកភស្តុតាងរបៀបនោះបានទេ។ ម្លោះហើយ គេគ្រាន់តែទាមទារនូវការអះអាងជាសាមញ្ញដូចនេះ។ ប្រសិនបើភស្តុតាង ដូចចម្លើយសារភាពទទួលបានតាមរយៈទារុណកម្ម ខ្លឹមសារចម្លើយនោះ ត្រូវបានបដិសេធទាំងស្រុងនិងមិនអនុញ្ញាតឲ្យយោងឡើយ។ ក៏ប៉ុន្តែ **អវតក** បានអះអាងបន្ថែមថា ព័ត៌មានមួយចំនួនក្នុងចម្លើយសារភាពដែលទទួលបាន ដោយមិនប្រើទារុណកម្ម អាចត្រូវបានប្រើប្រាស់ជាព័ត៌មានបាន។ បុគ្គលមានក្នុងចម្លើយសារភាព អាចត្រូវកោះសួរ ហើយសក្ខីកម្មរបស់ពួកគេ អាចត្រូវបានទទួលយកដោយតុលាការ។